**សុន្ទរកថា**
**លោកជំទាវ នាង ចំន្ទថារណា ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា**
**ថ្លែងក្នុងឱកាសបើកសិក្ខាសាលាស្តីពី "ការប្រឆាំងការសម្អាតប្រាក់"**
**ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៨ នៅធនាគារជាតិនៃកម្ពុជា**
***********

សូមគោរព

- **លោក Jean Pierre MICHAU ទីប្រឹក្សាទេសាភិបាលធនាគារកណ្តាលបារាំង**
- **លោក លោកស្រី និងអ្នកនាងកញ្ញា ជាសិក្ខាកាមទាំងអស់ ជាទីមេត្រី !**

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយក្រៃលែង និងសូមសម្តែងការស្វាគមន៍យ៉ាងកក់ក្តៅចំពោះ លោក Jean Pierre MICHAU ទីប្រឹក្សាទេសាភិបាលធនាគារកណ្តាលបារាំង និងអស់លោក លោកស្រី និងនាងកញ្ញាជាសិក្ខាកាមទាំងអស់ដែលបានឆ្លៀតឱកាសដ៏មានតម្លៃចូលរួមនៅក្នុងសិក្ខាសាលាស្តីពី "ការប្រឆាំងការសម្អាតប្រាក់" ដែលបានរៀបចំឡើងនៅធនាគារជាតិនៃកម្ពុជានៅក្នុងថ្ងៃនេះ ។

សិក្ខាសាលានេះ ជាសិក្ខាសាលាលើកទីបីរបស់លោក Jean Pierre MICHAU ដែលត្រូវបានធ្វើឡើងក្នុងគោលបំណងបណ្តុះបណ្តាលឱ្យបានកាន់តែទូលំទូលាយបន្ថែមទៀត អំពីការប្រឆាំងការសម្អាតប្រាក់ដល់បុគ្គលរាយការណ៍ទាំងអស់ ដែលជាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងមន្ត្រីរបស់ធនាគារជាតិនៃកម្ពុជា ដែលជាអាជ្ញាធរត្រួតពិនិត្យឱ្យយល់ដឹងពីកាតព្វកិច្ច តួនាទី និងការទទួលខុសត្រូវក្នុងការអនុវត្តច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលបានប្រកាសឱ្យប្រើប្រាស់កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ និងប្រកាសស្តីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលបានប្រកាសឱ្យប្រើប្រាស់កាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៨ កន្លងទៅនេះ ។

**លោក លោកស្រី និងនាងកញ្ញា ជាសិក្ខាកាមទាំងអស់ ជាទីមេត្រី !**

ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ជាប្រធានបទមួយដ៏ក្តៅគគុក និងសំខាន់បំផុត ដែលប្រទេសនៅក្នុងតំបន់ និងពិភពលោកកំពុងយកចិត្តទុកដាក់ការពារ ទប់ស្កាត់ និងលុបបំបាត់ ដោយសារតែស្ថានភាពបច្ចុប្បន្ននៃអំពើភេរវកម្មអន្តរជាតិកំពុងរាលដាល និងគំរាមកំហែងដល់សុវត្ថិភាពប្រជាជន ស្ថិរភាពសង្គម និងដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ តំបន់ និងពិភពលោក ហើយទំហំនៃការបំផ្លាញហេដ្ឋារចនាសម្ព័ន្ធជារូបវ័ន្តមានលក្ខណៈធ្ងន់ធ្ងរ មានអង្គការចាត់តាំងជាខ្សែសង្វាក់ឆ្លងដែន *ជាពិសេស* មានការគាំទ្រផ្នែកហិរញ្ញវត្ថុមកពីប្រភពផ្សេងៗ ។

ជារឿយៗ *អ្នកសម្អាតប្រាក់* បានប្រើប្រាស់ប្រព័ន្ធហិរញ្ញវត្ថុ ដែលជាស្នូលនៃការអភិវឌ្ឍសេដ្ឋកិច្ចសម្រាប់សម្អាតប្រាក់របស់ខ្លួន ។ ចំណែកឯ *ពួកភេរវករ* វិញ ក៏តែងតែសម្លឹងមើលភាពធូររលុង ឬចន្លោះប្រហោងនៃទំនាក់ទំនង និងសហប្រតិបត្តិការរវាងបញ្ញត្តិករ និងភ្នាក់ងារអនុវត្តច្បាប់នេះ ដើម្បីទាញយកផលប្រយោជន៍ពីចំណុចប្រហោងទាំងនោះ ដោយប្រើប្រាស់ស្ថាប័នហិរញ្ញវត្ថុ និងស្ថាប័នដែលពាក់ព័ន្ធនានា ក្នុងគោលបំណងដើម្បីយកទៅធ្វើវិច្ឆេទកម្ម

ផ្នែកនយោបាយ ធ្វើឱ្យប្រជាពលរដ្ឋស្លូតត្រង់ស្លាប់ និងបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច និងសង្គមរបស់ប្រទេសមួយឱ្យខូចខាត ។

ដូច្នេះ ដើម្បីឱ្យប្រទេសកម្ពុជាក្លាយជាប្រទេសមួយ ដែលប្រព័ន្ធធនាគារទាំងមូលចៀសផុតពីការរំលោភបំពានដោយក្រុមអ្នកសម្អាតប្រាក់ និងភេរវជន ការសហការយ៉ាងជិតស្និតរបស់ស្ថាប័នហិរញ្ញវត្ថុទាំងអស់មានសារៈសំខាន់ណាស់ក្នុងការពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិឱ្យបានហ្មត់ចត់ និងប្រកបដោយប្រសិទ្ធភាព ហើយការអនុវត្តនេះនឹងផ្តល់នូវអត្ថប្រយោជន៍ និងទំនុកចិត្តពីសំណាក់ធនាគារទំនាក់ទំនងមកលើប្រព័ន្ធធនាគារ ដែលកំពុងប្រកបអាជីវកម្មនៅក្នុងប្រទេសកម្ពុជា ។

**លោក លោកស្រី និងនាងកញ្ញា ជាសិក្ខាកាមទាំងអស់ ជាទីមេត្រី !**

ទោះបីសិក្ខាសាលានេះមានរយៈពេលខ្លីក៏ដោយ តែជាសិក្ខាសាលាមួយដែលមានសារៈសំខាន់សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងមន្ត្រីត្រួតពិនិត្យ ដោយបានផ្តល់ជាពន្លឺមួយឱ្យយល់ដឹងកាន់តែស៊ីជម្រៅអំពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម តួនាទី និងភារកិច្ចរបស់ខ្លួននៅក្នុងការអនុវត្តតាមច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងទទួលបានចំណេះដឹងដ៏ទូលំទូលាយផ្សេងៗទៀតពីគ្រូឧទ្ទេសនាម និងជាការដោះដូរបទពិសោធន៍គ្នាទៅវិញទៅមកផងដែរ ។

ជាទីបញ្ចប់ ខ្ញុំសូមឆ្លៀតឱកាសនេះសម្តែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះធនាគារកណ្តាលនៃប្រទេសបារាំងដែលតែងតែបន្តការគាំទ្ររាល់ការខិតខំប្រឹងប្រែងអភិវឌ្ឍន៍ប្រទេសកម្ពុជា ពិសេស ធនាគារជាតិនៃកម្ពុជា និងសូមថ្លែងអំណរគុណលោក Jean Pierre MICHAU ដែលបានចំណាយពេលផ្តល់បទឧទ្ទេសនាម និងផ្តល់បទពិសោធន៍ល្អៗសម្រាប់អង្គសិក្ខាសាលានៅថ្ងៃនេះ ហើយសង្ឃឹមថា យើងនឹងមានកិច្ចសហប្រតិបត្តិការគ្នាយ៉ាងរឹងមាំទៅថ្ងៃអនាគតខាងមុខទៀត ។

ខ្ញុំសូមជូនពរលោក Jean Pierre MICHAU អស់លោក លោកស្រី និងនាងកញ្ញាជាសិក្ខាកាមដែលមានវត្តមាននៅទីនេះ សូមមានប្រាជ្ញាវៀងវៃ សុខភាពបរិបូរណ៍ កម្លាំងមាំមួន និងទទួលបានជ័យជំនះគ្រប់ភារកិច្ច ហើយសូមឱ្យសិក្ខាសាលានេះទទួលបានលទ្ធផលផ្លែផ្កាល្អគួរជាទីគាប់ចិត្ត ។

ខ្ញុំសូមប្រកាសជាផ្លូវការបើកសិក្ខាសាលាស្តីពី “ការសម្អាតប្រាក់”ចាប់ពីពេលនេះតទៅ ។

**សូមអរគុណ!**